ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១០៤/រយក./១៨

# របាយការណ៍បូកសរុប
## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែមេសា និងទិសដៅខែឧសភា ឆ្នាំ២០១៨

### I. ស្ថានភាពទូទៅ

ក្នុងខែមេសា ឆ្នាំ២០១៨ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាបជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយស្ថាប័ន អន្តរក្រសួង និងអង្គភាពពាក់ព័ន្ធនានា ជាពិសេសលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ក្រោមជាតិ។ ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតី រហូតដល់រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានមានប្រសាសន៍នៅក្នុងកម្មវិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ប្រចាំ ២០១៧ របស់រដ្ឋបាលខេត្តបាត់ដំបង និងបញ្ជាក់ថា "**ឆ្នាំ២០១៨ ត្រូវបិទច្រករបៀងឲ្យបាន**" ពីព្រោះវាមិនមែនតែទំនិញគេចពន្ធ និងគ្រឿងញៀនទេ វាជាច្រកមានការរត់ពន្ធមនុស្ស ជួញដូរមនុស្ស ដែលជាបញ្ហាគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋ យើងត្រូវបានគេនាំចេញទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ រហូតដល់ជាងមួយលាននាក់ទាំងស្របច្បាប់ ទាំងមិនមានឯកសារច្បាប់លាស់ និងការខាតបង់ថវិកាជាតិរាប់លានដុល្លារ។ ក្រោយពីរាជរដ្ឋាភិបាលថៃបានចេញគោលការណ៍រឹតបន្តឹងពលករទេសសន្តរប្រវេសន៍ ធ្វើការខុសច្បាប់ក្នុងប្រទេសថៃរួចមក ដើម្បីជាដំណោះស្រាយ ប្រមុខរាជរដ្ឋាភិបាលរបស់យើង បានយកចិត្តទុកដាក់បំផុតចំពោះប្រជាពលរដ្ឋ ធ្វើទេសន្តរប្រវេស៍នៅក្រៅប្រទេស និងបានសហការជាមួយរដ្ឋាភិបាលថៃ ក្នុងការជំរុញឲ្យមានការរៀបចំផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ជាពិសេសត្រូវបានពិភាក្សាជាមួយភាគីថៃ ដើម្បីការការពារសុវត្ថិភាព សិទ្ធិការងារ ក្នុងនោះរួមមានរបបគ្រោះថ្នាក់ការងារ របបថែទាំសុខភាព និងប្រាក់សោធននិវត្តន៍ជូនដល់ពលករកម្ពុជា ឲ្យដូចពលករថៃដែរ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** ជាសេនាធិការ បានបន្តសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ ប្រមូលផ្តុំកម្លាំងចូលរួមរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរកដំណោះស្រាយបញ្ហាប្រឈមនានា។ របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបាន ៖

- ពីបណ្ដាក្រសួង ស្ថាប័ន ថ្នាក់ជាតិ មានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការពារជនរងគ្រោះ) និងអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានផ្ដល់របាយការណ៍។
- សម្រាប់បណ្ដាស្ថាប័ន ថ្នាក់ក្រោមជាតិ មានលេខាធិការដ្ឋាន២១រាជធានី-ខេត្ត បានផ្ដល់របាយការណ៍។ ដោយឡែកខេត្តព្រះសីហនុ បន្ទាយមានជ័យ ស្វាយរៀង និងខេត្តកំពង់ឆ្នាំង មិនបានផ្ដល់របាយការមកលេខាធិការដ្ឋាន គ.ជ.ប.ជ។

ជាលទ្ធផល ដែលសម្រេចបានក្នុងខែមេសា ឆ្នាំ២០១៧នេះ មានដូចខាងក្រោម៖

## ការអនុវត្តផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ក.១-ច្បាប់ គោលនយោបាយ និងឯកសារកិច្ចសហប្រតិបត្តិការកំពុងរៀបចំ៖

ក.១.១-<u>សេចក្ដីព្រាងច្បាប់ដែលកំពុងរៀបចំ</u>៖

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានដឹកនាំធ្វើសេចក្ដីព្រាងច្បាប់ ស្ដីពី"**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្ដីព្រាងច្បាប់៖
  - ស្ដីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
  - ស្ដីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

ក.១.២-<u>សន្ធិសញ្ញាកំពុងរៀបចំ</u>៖

- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្ដីព្រាងសន្ធិសញ្ញា ទ្វេភាគី៖
  - **ស្ដីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"**
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
  - **ស្ដីពី"បត្យាប័ន"**
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
  - **ស្ដីពី "បញ្ជូនទណ្ឌិត"**
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

ក.១.៣-<u>អនុស្សរណៈបានចុះហត្ថលេខារួច</u>៖

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយ**អង្គការអន្តរជាតិ** GVC ស្ដីពីការគាំទ្រ និងការតស៊ូមតិលើសិទ្ធិពលករទេសន្តប្រវេសន៍កម្ពុជា ក្នុងប្រទេសថៃ ដើម្បីបង្ការ ទប់ស្កាត់ ការរំលោភបំពាន និងអំពើជួញដូរមនុស្ស (ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨)។

ក.១.៤-**អនុស្សរណៈកំពុងរៀបចំ៖**

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសឥណ្ឌា ស្តីពី "**កិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស**"(ដើមឆ្នាំ ២០១៨)។
- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- **ក្រសួងសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្តីពីការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

ក.១.៥-**បទដ្ឋានគតិយុត្តិ កំពុងរៀបចំ៖**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តលក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ**"។
- **ក្រសួងអប់រំ យុវជន និងកីឡា៖** ធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**"។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រិត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ.ការបង្ការទប់ស្កាត់

### ខ.១-កាត់បន្ថយភាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ៖

រដ្ឋបាលខេត្តបាត់ដំបង ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ សរុបចំនួន**៣.៣៨៦**ក្បាល ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន។

### ខ.២-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

នៅខែមេសា ឆ្នាំ២០១៨នេះ **ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ** មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចសហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោលបាយ "**ភូមិ-ឃុំមានសុវត្ថិភាព**" ដល់អាជ្ញាធរមូលដ្ឋាន សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន**៣.៦២១**លើក មានអ្នកចូលរួមសរុបចំនួន**៣៧៥.១៨៧**នាក់ (បើប្រៀបធៀបនឹងខែមុន មានចំនួនត្រឹមតែ**៣១៤.៤៥៤**នាក់) កើនឡើងចំនួន**៦០.៧៣៣**នាក់ ស្មើនឹង**១៩.៣១%** ក្នុងនោះស្ត្រីមានចំនួន**២០៣.៧៤៣**នាក់។ (**ឧបសម្ព័ន្ធទី១**)

### ខ.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- **លេខាធិការដ្ឋានគ.ខ.ប.ជខេត្ត** បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាម

ប៉ុស្តិ៍វិទ្យុចំនួន៩៩លើក (ខេត្តកោះកុង៩០លើក សៀមរាប០៩លើក)។

- **ខេត្តបាត់ដំបង អង្គការ Samaritan Purse** បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ពលករចំណាកស្រុក១៧៦នាក់ ស្រី៧៨នាក់ ដែលបញ្ជូនត្រឡប់នៅព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

**ខ.៤-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស**

**ខ.៤.១-វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖**

អគ្គស្នងការដ្ឋាននគរបាលជាតិ (**របាយការណ៍ពីក្រុមការងារអនុវត្តន៍ច្បាប់**) និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- បច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន៤២១គោលដៅ មានមនុស្សចំនួន១.៨៤៥នាក់ (ស្រី១.៥០៩នាក់) **កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្ត មានខេត្ត៖** (តាកែវ កែប ក្រចេះ រតនគិរី កំពង់ឆ្នាំង ស្វាយរៀង និងកោះកុង)។
- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៦គោលដៅ សរុបចំនួន៧៥គោលដៅទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន២២លើក ខេត្តអនុវត្តមាន៖ ស្វាយរៀង ឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង និងព្រៃវែង។

**ខ.៥-គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់**

**ខ.៥.១-វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក**

- បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន៣២២.៨៦៧នាក់ (ស្រី១៤៧.៩៥៨នាក់) អនីតិជន៩.០៩០នាក់ (ស្រី៣.៥០៨នាក់) ក្នុងនោះស្របច្បាប់ចំនួន១៨៣.០៦៤នាក់ (ស្រី៩១.៦៤៨នាក់) អនីតិជន១.៨០៦នាក់ (ស្រី៧៧៦នាក់) មិនស្របច្បាប់ចំនួន១៣៩.៨០៣នាក់ (ស្រី៥៦.៣១០នាក់) អនីតិជន៧.២៨៤នាក់ (ស្រី២.៧៣២នាក់) បើប្រៀបធៀបនឹងខែមុនមានការកើនឡើងចំនួន៦២.៦៣៩នាក់ ស្មើនឹង២៤.០៧%។

**ខ.៥.២-ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន**

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍អន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន១៦១លើក មនុស្សចំនួន៣.៤៥៤នាក់ (ស្រី១.១៤២នាក់ កុមារ២៩២នាក់)។ ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន៣៤លើក មនុស្ស៧៣នាក់ ស្រី២៨នាក់ និងតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន១២៧លើក មនុស្ស៣.៣៨១នាក់ (ស្រី១.១១៤នាក់ កុមារ ២៩២នាក់)។

*ស្ថានភាព ៖*

- **ក្រុមការងារអនុវត្តច្បាប់**បានរាយការណ៍ថា មានពលរដ្ឋខ្មែរចំនួន៥៣នាក់ (ស្រី១១នាក់)

ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។

- **អគ្គបញ្ជាការដ្ឋាន ទីចាត់ការការងារព្រំដែន** បានទទួល និងសម្ភាសន៍ពលករខ្មែរដែលអាជ្ញាធរថៃបញ្ជូនមកវិញ តាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ចំនួន**៣.២៦៦**នាក់ ស្រី**១.០៣៧**នាក់ អនីតិជនចំនួន**៣១០**នាក់។
- **ខេត្តបាត់ដំបង** បានទទួលពលករខ្មែរដែលអាជ្ញាថៃបញ្ជូនត្រឡប់មកវិញ ចំនួន**១៦**លើក មនុស្សចំនួន**៣១០**នាក់ ស្រី**១២៧**នាក់ កុមារ**១០**នាក់។
- **ខេត្តប៉ៃលិន** បានទទួលពលករខ្មែរដែលអាជ្ញាថៃបញ្ជូនត្រឡប់មកវិញ ចំនួន**១៩**លើក មនុស្សចំនួន**៥០៥**នាក់ ស្រី**២១៦**នាក់។
- **ដោយឡែក** យោងរបាយការណ៍**អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានបង្ហាញថាមានជនបរទេសធ្វើការនៅកម្ពុជាដោយខុសច្បាប់ ត្រូវបានរកឃើញដូចខាងក្រោម ៖

**១-<u>ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់:</u>** ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន**៥៥**លើក មនុស្សចំនួន**១៩៥**នាក់ ស្រី**៣៥**នាក់ មាន**៣០**សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ ៖

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចំនួន**២៦**លើក មនុស្ស**១៥១**នាក់ ស្រី**៣២**នាក់ មាន**១៧**សញ្ជាតិ។
- បដិសេធមិនឲ្យចូលប្រទេសតាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន**២៩**លើក មនុស្សចំនួន**៤៤**នាក់ មាន**១៤**សញ្ជាតិ។

**២-បទល្មើសស្នាក់នៅខុសច្បាប់ ៖**

- ករណីស្នាក់ខុសច្បាប់ មនុស្សចំនួន០៨នាក់ ស្រី០១នាក់ មាន០៦សញ្ជាតិ (ឥណ្ឌា០១នាក់ អង់គ្លេស០១នាក់ វៀតណាម០៣នាក់ស្រី០១នាក់ បារាំង០១នាក់ សឹង្ហបុរី០១នាក់ និងរ៉ូម៉ានី០១នាក់)។

**ខ.៦-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស**

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន**១៣៥**គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរចំនួន**១០**នាក់ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## <u>គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស</u>

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពីអង្គភាពចំនួន**៧** គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

ក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋានរាជធានី-ខេត្ត (រាជធានីភ្នំពេញ កំពង់ឆ្នាំង កណ្តាល ព្រះវិហារ ព្រះសីហនុ)។

**គ.១-ការងារអនុវត្តច្បាប់**

គ.១.១-<u>ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ</u>

អគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន០៧/០៧ករណី (បើប្រៀបធៀបនឹងខែមុនស្មើគ្នា) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ០៨នាក់ (ស្រី០១នាក់)។ យើងបានសង្គ្រោះជនរងគ្រោះចំនួន០៩នាក់ មានអាយុក្រោម១៥ឆ្នាំ០៨នាក់ និង អាយុ១៨ឆ្នាំឡើង០១នាក់ (ប្រគល់ឲ្យគ្រួសារទាំងអស់)។

**១.ករណីអំពើជួញដូរមនុស្ស៖**

បង្ក្រាបបាន០១/០៣**ករណី** (ថយចុះចំនួន០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន០២នាក់ (ស្រី០១នាក់) និងសង្គ្រោះជនរងគ្រោះចំនួន០១នាក់ អាយុ១៨ឆ្នាំឡើងចំនួន០១នាក់ (ប្រគល់ឲ្យគ្រួសារទាំងអស់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០១ | ០២ |

**២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖**

បង្ក្រាបបាន០៦/០៤**ករណី** (កើនឡើងចំនួន០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន០៦នាក់ និង សង្គ្រោះជនរងគ្រោះចំនួន០៨នាក់ អាយុក្រោម១៥ឆ្នាំ០៨នាក់ (ប្រគល់ឲ្យគ្រួសារទាំងអស់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥ |
| -អំពើអាសប្រចាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ |
| *សរុប* | *០៦ ករណី* | *០៦ នាក់* |

## ឃ.<u>កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ</u>

**ឃ.១-ការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និងជនសង្ស័យ**

- យោងស្ថិតិ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានបញ្ជូនពលរដ្ឋខ្មែររងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការ IOM មានចំនួន៤៥នាក់ ស្រី៣៣នាក់ មកពី ៖

- ប្រទេសម៉ាឡេស៊ី ចំនួន២៥នាក់ (ស្រី១៩នាក់)

- ប្រទេសវៀតណាម ចំនួន១៤នាក់ (ស្រី០៩នាក់)
- ប្រទេសចិន ចំនួន០៥នាក់ (ស្រី០៥នាក់)
- ប្រទេសឡាវ ចំនួន០១នាក់។

*__ស្ថាប័ន-អង្គភាពអនុវត្តមាន ៖__*

○ **អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍តាមក្រុមការងារអនុវត្តន៍ច្បាប់)** បានទទួលពលករខ្មែររងគ្រោះចំនួន០៦នាក់(ស្រី០១នាក់) ក្នុងនោះមកពីប្រទេសម៉ាឡេស៊ី០៥នាក់ និងប្រទេសចិន០១នាក់(ស្រី)។ តាមការសម្ភាសទៅតាមមេខ្យល់០១នាក់ និង០៥នាក់ទៀតទៅដោយខ្លួនឯង។

**ឃ.២-ការទទួលជនសង្ស័យរងគ្រោះ**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាសរុបចំនួន១៩នាក់ (ស្រី១១នាក់) កុមារ០៧នាក់ (កុមារី០៦នាក់)។ មានដូចខាងក្រោម៖

- បានទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន១០នាក់(ស្រី) ក្នុងនោះមកពី៖ ប្រទេសចិន០៦នាក់ ម៉ាឡេស៊ី០២នាក់ និងវៀតណាម០២នាក់ ករណីជួញដូរផ្លូវភេទ០៨នាក់(រៀបការក្លែងក្លាយ) និងករណីជួញដូរកម្លាំងពលកម្ម ដោយមានការសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ អង្គការលីកាដូ និងអង្គការមេត្រីអន្តរជាតិ។

- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានទទួលជនរងគ្រោះមាតុភូមិនិវត្តពីប្រទេសថៃចំនួន០៤នាក់(កុមារី) ករណីជួញដូរកម្លាំងពលកម្ម និងបានទទួលមុខសញ្ញារងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស (នីរទេស) ចំនួន០៥នាក់ (ស្រី០១នាក់ បុរស០១នាក់ កុមារី០២នាក់ កុមារ០១នាក់)។ ក្នុងនោះមាន: ករណីងាយរងគ្រោះ០៣នាក់ ករណីអំពើហឹង្សាក្នុងគ្រួសារ០១នាក់(ស្រី) និងករណីរំលោភផ្លូវភេទ០១នាក់(កុមារី)។

**ឃ.៣-ការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅទទួលសេវាស្នាក់នៅ(រយៈពេលវែង-ខ្លី) និងស្តារនីតិសម្បទា**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិម្បទាចំនួន៥២នាក់ (ស្រី២៣នាក់) ក្នុងនោះមាន៖

- បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន៣៧នាក់ (ស្រី១៦នាក់) ទៅទទួលសេវានៅអង្គការដៃគូដូចជា: អង្គការសម្ព័ន្ធចាប់ដៃ០៦នាក់ អង្គការមេត្រីអន្តរជាតិ០៣នាក់ អង្គការយុត្តិធម៌អន្តរជាតិ២៧នាក់ និងអង្គការលីកាដូ០១នាក់។

- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានធ្វើការសម្ភាស និងបានទំនាក់ទំនងបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះ ចំនួន០៨នាក់ ទៅអង្គការដៃគូដូចជា: អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ០២នាក់ អង្គការក្តីសង្ឃឹម និងយុត្តិធម៌០២នាក់ អង្គការដំណក់ទឹក០២នាក់ អង្គការគ្រួសារថ្មី០២នាក់ ដើម្បីទទួលសេវាស្នាក់នៅសុវត្ថិភាព អប់រំក្នុង និងក្រៅប្រព័ន្ធបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងសេវាផ្សេងៗទៀត។

- **មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ** បានបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០៣នាក់(ស្រី) ទៅទទួលសេវានៅមណ្ឌលរបស់អង្គការដៃគូដើម្បីស្តារនីតិសម្បទា។

• **អង្គការរតនៈអន្តរជាតិ** បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃក្នុងការផ្តល់សេវា ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០៤នាក់(ស្រី) និងផ្តល់ថវិកាឧបត្ថម្ភដល់ជនរងគ្រោះសម្រាប់ធ្វើដំណើរត្រឡប់ទៅផ្ទះវិញដោយខ្លួនឯង។

**ឃ.៤-ការធ្វើសមាហរណកម្មជួយជនរងគ្រោះ និងជនងាយរងគ្រោះ** (ក្រុមការពារជនរងគ្រោះ)

- ការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចខេត្តស្វាយរៀង សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រឡប់ទៅគ្រួសារ និងសហគមន៍វិញ សរុបចំនួន១៤នាក់ (ស្រី០៩នាក់)។

## II. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

#### ១.១-ការបណ្តុះបណ្តាលក្នុងប្រទេស

លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ចំនួន០២ គឺមានខេត្តក្រចេះ និងខេត្តកំពង់ធំ បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាល បានចំនួន០៨វគ្គ មានសិក្ខាកាមចូលរួមចំនួន**៥៩៩**នាក់ ក្នុងនោះមានស្ត្រី**២៦៣**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក គ.ខ.ប.ជ លោកគ្រូ អ្នកគ្រូ ប្រតិបត្តិករទេសចរណ៍នៅតាមសណ្ឋាគារ និងប្រជាពលរដ្ឋ មានតារាងលម្អិតខាងក្រោម៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រចេះ** បានបើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារជនរងគ្រោះ ការទប់ស្កាត់អំពើជួញដូរមនុស្ស ការលោកបំពាន និងការធ្វើអាជីវកម្មផ្លូវភេទ។ | ០៧ | ៣០៥ | ១៥៧ |
| ២ | **លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តកំពង់ធំ** បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពជនបង្គោលស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា នៅគ្រប់រដ្ឋបាលក្រុង ស្រុកទាំង៨ ក្នុងខេត្តកំពង់ធំ។ | ០១ | ២៩៤ | ១០៦ |
| **សរុប** | | **០៨** | **៥៩៩** | **២៦៣** |

#### ១.២-ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ

សរុបការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ**៤៧**លើក មានអ្នកចូលរួមសរុប៥៨១នាក់ មានស្រី**២៧៣**នាក់ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន**២៤**លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំនួន**០៥**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន១៨លើក ។ (**ឧបសម្ព័ន្ធទី២**)

### ១. ក្រៅប្រទេស

#### ១.១-ទស្សនៈកិច្ច

- **ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្នុងដំណើរទស្សនៈកិច្ចការងារខេត្ត KHANH HOA នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

## III. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជាគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

### គ.សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្ដល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ/ខ.ប.ជ រាជធានី/ខេត្ត ល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ ដើម្បីប្រសិទ្ធភាពការងារ។
- បើកវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្ដីសម្រេច ស្ដីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្ដេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## IV. ទិសដៅខែឧសភា ឆ្នាំ២០១៨

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. រៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ពាក់កណ្ដាលអាណត្តិទី២៖២០១៧-២០១៨)។

៤. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៥. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៦. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៧. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៨. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៩. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១០. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១១. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១២. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាព សម្រាប់ដំណាក់កាលដ៏ចាំបាច់៖

## ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងខែមេសា ឆ្នាំ២០១៨

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 86 លើក | 5,568 នាក់ | 2,451 នាក់ |
| 2 | ខេត្តកណ្ដាល | វេទិកាសាធារណៈ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 286 លើក | 13,728 នាក់ | 7,550 នាក់ |
| | | ផ្សព្វផ្សាយ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ប្រជាពលរដ្ឋ និងបញ្ជ្រាបអំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈការប្រជុំ។ | ក្រុមការងារថ្នាក់ស្រុក និងមន្ទីរអប់រំយុវជន និងកីឡា | 47 លើក | 1,450 នាក់ | 647 នាក់ |
| 3 | ខេត្តតាកែវ | វេទិកាសាធារណៈ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 9 លើក | 436 នាក់ | 160 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | មន្ទីរកិច្ចការនារីខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត | 96 លើក | 13,452 នាក់ | 3,300 នាក់ |
| 4 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្សដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 170 លើក | 4,863 នាក់ | 2,602 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅតាមវិទ្យាល័យ អនុវិទ្យាល័យទាំង២០ ទូទាំងខេត្តពោធិ៍សាត់ សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ។ | ស្នងការដ្ឋាននគរបាលខេត្ត | 594 លើក | 227,960 នាក់ | 130,472 នាក់ |
| 5 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្ដីពីការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 585 លើក | 32,757 នាក់ | 16,958 នាក់ |
| | | វេទិកាសាធារណៈ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 353 លើក | 11,759 នាក់ | 5,814 នាក់ |
| 6 | ខេត្តសៀមរាប | ផ្សព្វផ្សាយ ស្ដីពីការអនុវត្តគោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ទូទាំងខេត្ត។ | ស្នងការដ្ឋាននគរបាលខេត្ត | 27 លើក | 2,921 នាក់ | 1,713 នាក់ |
| | | ផ្សព្វផ្សាយ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងកិច្ចការពារជនរងគ្រោះ ដល់ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 9 លើក | 545 នាក់ | 332 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 7 | ខេត្តរតនគិរី | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 73 លើក | 5,270 នាក់ | 2,377 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈការប្រជុំជាមួយគ្រូបង្រៀន ដើម្បីធ្វើការណែនាំឲ្យសិស្ស សរសេរបងារ ពាក្យស្លោកដែលមានខ្លឹមសារ ប្រឆាំងការជួញដូរមនុស្ស ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មពលកម្មលើកុមារ និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ។ និងផ្សព្វផ្សាយ ទៅដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន សិប្បកម្មនានា ក្នុងខេត្ត ឲ្យអនុវត្តតាមច្បាប់ស្តីពីការងារ។ | មន្ទីរអប់រំយុវជនខេត្ត និង មន្ទីរ ការងារខេត្ត | 15 លើក | 7,039 នាក់ | 2,852 នាក់ |
| 8 | ខេត្តកំពង់ចាម | ផ្សព្វផ្សាយ ស្តីពីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1,253 លើក | 44,494 នាក់ | 24,763 នាក់ |
| | | ផ្សព្វផ្សាយពីគោលនយោបាយទេសន្តប្រវេសន៍ការងារ អនុក្រឹត្យ និងប្រកាសរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្សព្វផ្សាយស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន។ | ក្រុមការងារគ.ខ.ប.ជខេត្ត និងមន្ទីរការងារខេត្ត | 2 លើក | 825 នាក់ | 502 នាក់ |
| 9 | ខេត្តត្បូងឃ្មុំ | វេទិកាសាធារណៈ តាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 1 លើក | 44 នាក់ | 32 នាក់ |
| 10 | ខេត្តកែប | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈ គោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 11 លើក | 1,869 នាក់ | 1,060 នាក់ |
| 11 | ខេត្តកោះកុង | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ដល់ប្រជាពលរដ្ឋ។ | មន្ទីរទេសចរណ៍ខេត្ត | 1 លើក | 24 នាក់ | 17 នាក់ |
| 12 | ខេត្តស្ទឹងត្រែង | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដល់ប្រជាពលរដ្ឋនៅថ្នាក់ភូមិ ចំនួន ០៣ភូម។ | មន្ទីរកិច្ចការនារីខេត្ត | 3 លើក | 183 នាក់ | 141 នាក់ |

សកម្មភាពសរុបចំនួន: 3,621 លើក

មនុស្សសរុបចំនួន: 375,187 នាក់

ស្រីសរុបចំនួន : 203,743 នាក់

## ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៤៧លើក) មនុស្សចំនួន៥៨១នាក់ (ស្រី២៧៣នាក់)

| **ស្ថាប័នសម្របសម្រួល** | **សកម្មភាព** |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | **សម្របសម្រួលចំនួន២៤លើក អ្នកចូលរួមសរុបចំនួន១០០នាក់ (ស្រី២១នាក់)**<br>លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>- បានអញ្ជើញជាប្រធានប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ចុះបំពេញបេសកកម្មតាមដានលើការអនុវត្តអនុសញ្ញាស៊ីដ (CEDAW) អនុសាសន៍សម្តេចតេជោនាយករដ្ឋមន្ត្រី និងច្បាប់ជាតិពាក់ព័ន្ធដែលទាក់ទងនឹងការលើកកម្ពស់ស្ថានភាព ជីវភាព ឋានៈ តួនាទី និងសុខមាលភាពស្ត្រី នៅខេត្តត្បូងឃ្មុំ។<br>- បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងការប្រឡងប្រណាំងការងារភូមិ-ឃុំមានសុវត្ថិភាព របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង។<br>- បានដឹកនាំ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ និងអគ្គលេខាធិការរង និងមន្ត្រី នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះសួរសុខទុក្ខ និងសំណេះសំណាលកងកម្លាំងនគរបាលវរៈការពារព្រំដែនទឹក គោក ចំនួន០៣ខេត្ត គឺខេត្តតាកែវ កំពត និងខេត្តកែប (វរៈការពារព្រំដែនលេខ ៦០១ ៤៣០ ២៤១ និងវរៈ៦០៣)។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីការពិភាក្សាត្រៀមរៀបចំកិច្ចប្រជុំផ្លាស់វេនជាមួយក្រសួងសន្តិសុខសាធារណចិន ដើម្បីពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការបង្ក្រាប និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចំនួន១៩នាក់ ស្រី០៦នាក់។<br>- បានដឹកនាំកិច្ចប្រជុំលើករណីបណ្តឹងរំលោភលើសេចក្តីទុក្ខចិត្ត និងការប៉ុនប៉ងនាំពលករចេញមិនស្របច្បាប់ទុកសម្រាប់ឆ្លងដែន របស់មជ្ឈមណ្ឌលភាសាជប៉ុនភ្នំពេញ-តូក្យូ និងមជ្ឈមណ្ឌលភាសាកូរ៉េ ជប៉ុន ដេជូដូ នៅសាលប្រជុំលោកជំទាវ សមាសភាពចូលរួមមានក្រុមការងារបង្ក្រាប ទប់ស្កាត់ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស។<br>- បានដឹកនាំកិច្ចប្រជុំក្រុមការងារបង្ក្រាប ទប់ស្កាត់ ស្តីពីការស្នើសុំកិច្ចសហការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការការងារជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងការដោះស្រាយបណ្តឹងក្រុមហ៊ុននាំពលករខុសច្បាប់ នៅសាលប្រជុំលោកជំទាវ។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង លើសេចក្តីព្រាងច្បាប់ ស្តីពី "**ការពពោះជំនួស**" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចំនួន១៦នាក់ ស្រី០៤នាក់។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីការវាយតម្លៃការផ្តល់ពិន្ទុប្រចាំឆ្នាំ២០១៧ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចំនួន១៨នាក់ ស្រី០៣នាក់។<br>- បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ០៦៦/១៨ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចំនួន១១នាក់ ស្រី០២នាក់។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអង្គការការីតាស ស្តីពីការរៀបចំកសាងមណ្ឌលសំចតសម្រាប់ពលករនៅក្រុងព្រះសីហនុ និងរៀបចំទិវាអន្តរសាសនាលើកទី២ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចំនួន២០នាក់ ស្រី០៤នាក់។ |

- បានដឹកនាំកិច្ចប្រជុំក្រុមជំនួយកិច្ចការទេន្តប្រវេសន៍ ស្តីពីផែនការការងារអ្វីជាអាទិភាពរបស់ក្រុម ដែលបានដាក់ឲ្យធ្វើពីពេលនេះរហូតដល់បំណាច់ឆ្នាំ២០១៨ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ពិភាក្សាស្តីពីពលករទេសន្តប្រវេសន៍ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចំនួន១៦នាក់ ស្រី០២នាក់។
- បានដឹកនាំកិច្ចប្រជុំការងាររវាងគណៈកម្មាធិការជាតិ គ.ជ.ប.ជ និង DSI ថៃ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

**១.ក្រុមជំនួយការបង្ការ ទប់ស្កាត់:**

- លោកប្រធានក្រុម និងមន្ត្រី បានជូនជនរងគ្រោះទៅសាលាដំបូង រាជធានីភ្នំពេញ ដើម្បីរងចាំការស៊ើបសួរពីព្រះរាជអាជ្ញារង លើករណីបណ្តឹង រំលោភសេចក្តីទុកចិត្ត និងការប៉ុនប៉ងនាំពលករចេញមិនស្របច្បាប់ទុកសម្រាប់ឆ្លងដែន របស់មជ្ឈមណ្ឌលភាសាជប៉ុន ភ្នំពេញ តូក្យូ និងមជ្ឈមណ្ឌលភាសាកូរ៉េ ជប៉ុន ដេជូដូ។
- ឯកឧត្តម ឧត្តមសេនីយ៍ទោ **ជីវ ផល្លី** អគ្គលេខាធិការរង បានដឹកនាំក្រុមការងារបង្ការ ទប់ស្កាត់ បើកកិច្ចប្រជុំជាមួយអង្គការ IJM លើករណីបណ្តឹងរំលោភលើសេចក្តីទុក្ខចិត្ត និងការប៉ុនប៉ងនាំពលករចេញមិនស្របច្បាប់ទុកសម្រាប់ឆ្លងដែនខុសច្បាប់ របស់មជ្ឈមណ្ឌលភាសាជប៉ុន ភ្នំពេញ-តូក្យូ និងមជ្ឈមណ្ឌលភាសាកូរ៉េ ជប៉ុន ដេជូដូ។

**២-ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ:**

- យោងតាមរបាយការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែររងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស បានសហការជាមួយអាជ្ញាធរនៅតាមតំបន់ មានចំនួន**៣០**នាក់ (ស្រី**០៧**នាក់ កុមារ១៧នាក់) មកពី ៖
  - ប្រទេសម៉ាឡេស៊ី ចំនួន១២នាក់ ស្រី០៧នាក់ កុមារ០២នាក់
  - ប្រទេសវៀតណាម ចំនួន១៤នាក់ កុមារ១១នាក់
  - ប្រទេសថៃ ចំនួន០៤នាក់ (កុមារអាយុចាប់ពី៣ឆ្នាំ ដល់១៣ឆ្នាំ)។

**៣-ក្រុមជំនួយកិច្ចការយុត្តិធម៌:**

- ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម រិយៈ** អគ្គលេខាធិការរង បានអញ្ជើញចូលរួមប្រជុំពិភាក្សាអំពីតម្រូវការបណ្តុះបណ្តាលជនជាមនុស្សនៅតាមអង្គភាព ដែលមានការចូលរួមរួមគ្រប់អគ្គចំណុះក្រសួងមហាផ្ទៃ រៀបចំដោយអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ។

**៤-ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ:**

- លោកជំទាវ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានដឹកនាំក្រុមការងារទំនាក់ទំនងអន្តរជាតិ ចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់ជាតិ អន្តរជាតិ ដែលពាក់ព័ន្ធការលើកកម្ពស់ស្ថានភាព ជីវភាពឋានៈ តួនាទី និងសុខមាលភាពស្ត្រី នៅខេត្តត្បូងឃ្មុំ។
- បានធ្វើការស្រាវជ្រាវរកព័ត៌មាន ពាក់ព័ន្ធនឹងសំណុំរឿងជួញដូរពលករនេសាទ កម្ពុជាចំនួន០៥នាក់ ទៅធ្វើការនៅលើទូកនេសាទថៃដែលនេសាទនៅ Sarawak នៅប្រទេសម៉ាឡាស៊ី និងទទួលរងការជិះជាន់ពីសំណាក់ទូកថៃ។
- ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ដែលដឹកនាំដោយលោកជំទាវ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានធ្វើការសម្របសម្រួល និងរៀបចំដើម្បីឲ្យមានកិច្ចប្រជុំពិភាក្សារវាងគណៈកម្មាធិការជាតិ គ.ជ.ប.ជ និង DSI ថៃ។

| | |
|---|---|
| | **៥-ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍:**<br>- លោកឧត្តមសេនីយ៍ត្រី **កែវ ផល្លា** ត្រូវបានចាត់បញ្ជូនទៅចូលរួមក្នុងកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ ជាមួយភាគីពាក់ព័ន្ធ ស្តីពីការលើកកម្ពស់សិទ្ធិនារី ដែលចំណាកស្រុកទៅក្រៅប្រទេសនៅក្នុងតំបន់អាស៊ានតាមកម្មវិធីសុវត្ថិភាព និងយុត្តិធម៌នៅសណ្ឋាគារ Raffle Hotel Le Royal នៅរាជធានីភ្នំពេញ រៀបចំដោយអង្គការ UN-WOMAN និង ILO។<br>- បានទំនាក់ទំនងទៅលោកវរសេនីយ៍ត្រី **សៀង ចន្ទី** នាយរងនគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិដូង ទទួលបន្ទុករដ្ឋបាល និងបច្ចេកវិទ្យាព័ត៌មាន ដើម្បីស្រាវជ្រាវរកឈ្មោះពលករទូកនេសាទ កម្ពុជា០២នាក់ ដែលបានស្លាប់ដោយកប៉ាល់ដឹកទំនិញរបស់ប៉ាគីស្ថានបុកទូកនេសាទថៃ Choke Chuchai នៅចំណុចឆ្នេរសមុទ្រសាត់តាហ៊ីប ខេត្តឈុនបុរី ប្រទេសថៃ កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៨ ។ ហើយបានរកឃើញជនរងទី១ ឈ្មោះ **សាយ វ៉ាង** ភេទប្រុស អាយុ៣០ឆ្នាំ រស់នៅស្រុកគីរីវង់ ខេត្តតាកែវ បានទទួលប្រាក់សំណងពីម្ចាស់កប៉ាល់ចំនួន**៣០**ម៉ឺនបាត ហើយសាច់ញាតិទទួលយកទៅធ្វើបុណ្យ។ ដោយឡែកជនរងគ្រោះទី២ ឈ្មោះ **ថែម សុខា** ភេទប្រុស អាយុប្រហាក់ប្រហែលគ្នា និងរស់នៅស្រុកជាមួយគ្នា ទទួលប្រាក់សំណងពីម្ចាស់កប៉ាល់ចំនួន**១០**ម៉ឺនបាតទេ ព្រោះសាច់ញាតិ របស់ពួកគេចង់បញ្ជូនបងប្អូនទៅធ្វើការលើទូកនេសាទនោះបន្ត។<br>- បានស្រង់ទិន្នន័យពលករខ្មែរចេញពីប្រទេសថៃមកលេងស្រុកកំណើត ចាប់ពីថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ២០១៨ មុនពេលបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ មានចំនួន**២៣.៣៦០**នាក់។<br>- បានស្រង់ទិន្នន័យពលករខ្មែរដែលវិលត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញ ក្រោយពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែររួច មានចំនួន**១៩.១៦៥**នាក់។<br>**៦-<u>ការងាររដ្ឋបាល</u>៖**<br>- លិខិតរបស់គណៈកម្មាធិការជាតិ៖ លិខិតចេញ(២១ច្បាប់) លិខិតចូល(០៣ច្បាប់)<br>- លិខិតរបស់អគ្គលេខាធិការដ្ឋាន៖ លិខិតចេញ(១០ច្បាប់) លិខិតចូល(១១ច្បាប់)។ |
| **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** | ❖ ឯកឧត្តម នាយឧត្តមសន្តិបណ្ឌិត **សុខ ផល** អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖<br>- បានទទួលជួបពិភាក្សាការងារជាមួយគណប្រតិភូនគរបាលជាតិសាធារណរដ្ឋកូរ៉េ ដឹកនាំដោយលោក IM BYUNG HO ប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសឧក្រិដ្ឋនៃការិយាល័យកិច្ចការបរទេស នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍។<br>- បានអញ្ជើញចូលរួមក្នុងឱកាស សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុញ្ញាតិឲ្យឯកឧត្តម VU QUANG MINH ឯកអគ្គរដ្ឋទូតវៀតណាមទើបតែងតាំងថ្មី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្តែងការគួរសម នៅសាលទទួលភ្ញៀវអន្តរជាតិ ទីស្តីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមក្នុងឱកាស សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុញ្ញាតិឲ្យឯកឧត្តម ឧត្តមសេនីយ៍ឯកបំរុង **ប៊ួយ វ៉ាន់ណាម** អនុរដ្ឋលេខាធិការក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្តែងការគួរសម នៅសាលទទួលភ្ញៀវអន្តរជាតិ ទីស្តីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ(S) ទីស្តីការក្រសួងមហាផ្ទៃ។<br>- បានទទួលជួបពិភាក្សាការងារជាមួយគណប្រតិភូ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងសន្តិសុខសាធារណរដ្ឋចិន ដែលដឹកនាំដោយលោក LIAO JINRONG អគ្គនាយកកិច្ចសហប្រតិបត្តិការអន្តរជាតិចិន នៅអគ្គនាយកដ្ឋានអន្តប្រវេសន៍។ |

| លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន១៨លើក អ្នកចូលរួមសរុបចំនួន៤៨១នាក់ (ស្រី២៥២នាក់) | |
|---|---|
| ខេត្តកណ្តាល | បានសម្របសម្រួលចំនួន០៦លើក អ្នកចូលរួមចំនួន១៥៧នាក់ ស្រី៨៥នាក់<br>- ក្រុមការងារថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន០៤លើក អ្នកចូលរួមចំនួន៧៨នាក់ ស្រី៤២នាក់។<br>- គណៈកម្មាធិការ គ.ខ.ប.ជ និងលេខាធិការដ្ឋានខេត្ត បានរៀបចំកិច្ចប្រជុំចំនួន០២លើក អ្នកចូលរួមចំនួន៧៩នាក់ ស្រី៤៣នាក់៖<br>○ កិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ អ្នកចូលរួមចំនួន៥០នាក់ ស្រី២៧នាក់<br>○ កិច្ចប្រជុំប្រចាំខែមេសា អ្នកចូលរួមចំនួន២៩នាក់ ស្រី១៦នាក់។ |
| ខេត្តសៀមរាប | បានសម្របសម្រួលចំនួន០៦លើក អ្នកចូលរួមចំនួន១១១នាក់ ស្រី៥៩នាក់<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំចំនួន០២លើក អ្នកចូលរួមចំនួន៧៩នាក់ ស្រី៤៣នាក់៖<br>○ កិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ អ្នកចូលរួមចំនួន៥១នាក់ ស្រី២២នាក់<br>○ កិច្ចប្រជុំប្រចាំខែមេសា អ្នកចូលរួមចំនួន៤៦នាក់ ស្រី២០នាក់។<br>- លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានអញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នារវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិល (GVC) ស្តីពីគម្រោងមីហ្គ្រា-វ៉ាយ គាំទ្រនិងការតស៊ូមតិលើសិទ្ធិពលករទេសន្តរប្រវេសន៍កម្ពុជា ក្នុងប្រទេសថៃ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រាជធានីភ្នំពេញ។<br>- អង្គការទេស្សនពិភពលោកខេត្តសៀមរាប បានប្រជុំជាមួយគណៈកម្មាធិការទទួលកិច្ចការនារី និងកុមារឃុំចន្លាសដៃ ស្រុកក្រឡាញ់ ដើម្បីស្វែងយល់ពីសមិទ្ធិផលតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ ស្តីពីការការពារកុមារ អ្នកចូលរួមចំនួន៣២នាក់ ស្រី១៦នាក់។<br>- មន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋានខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន០២លើក ស្តីពី (ការប្រយុទ្ធប្រឆាំងការរំលោភបំពានផ្លូវភេទលើអនីតិជន និងកិច្ចការពារកុមាររងគ្រោះ)។ |
| ខេត្តព្រៃវែង | បានសម្របសម្រួលចំនួន០២លើក អ្នកចូលរួមចំនួន៥៦នាក់ ស្រី១៧នាក់<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី១ អ្នកចូលរួមចំនួន៣១នាក់ ស្រី១៧នាក់។<br>- លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងវគ្គបណ្តុះបណ្តាលរបស់អង្គការសម្ព័ន្ធចាប់ដៃលើប្រធានបទ (ស្តីពីការទប់ ស្កាត់អំពើជួញដូរមនុស្ស និងរាល់ទម្រង់នៃការកេងប្រវ័ញ្ច) នៅសាលាស្រុកស្វាយអន្ទរ ខេត្តព្រៃវែង អ្នកចូលរួមចំនួន២៥នាក់។ |
| ខេត្តកំពង់ចាម | - បានចូលកិច្ចប្រជុំ ស្តីពីនីតិវិធីទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស ដែលប្រព្រឹត្តទៅនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម។ |
| ខេត្តស្ទឹងត្រែង | - បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(ស៊ី-ដ) នៅខេត្តក្រចេះ។ |
| ខេត្តតាកែវ | - លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយពង្រឹងការងារជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅស្រុកកោះអណ្តែត អ្នកចូលរួមចំនួន១៣២នាក់ ស្រី៨០នាក់។ |
| ខេត្តឧត្តរមានជ័យ | - ចូលរួមកិច្ចប្រជុំ គ ក ស ក នៅសាលាខេត្ត អ្នកចូលរួមចំនួន២៥នាក់ ស្រី១១នាក់។ |

១៣. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងដំណាក់កាលនៃការជំរុញដំណោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

១៤. បង្កើតក្រុមការងារ ពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល។

១៥. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជាអនុព័ន្ធការងារ ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម។

១៦. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.................ខែ..........ឆ្នាំ.........សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៥..........ខែមិថុនា..........ឆ្នាំ២០១៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ.ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ